ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកស្ទឹងសែន ទៅជាក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង សុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សម្រេច

មាត្រា ១.-

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកស្ទឹងសែន ស្រុកសន្ទុក និង ស្រុកកំពង់ស្វាយ នៃខេត្តកំពង់ធំ ដោយកាត់យកឃុំចំនួនបីចេញពីស្រុកស្ទឹងសែន គឺ ឃុំត្បូងក្រពើ បញ្ចូលទៅក្នុងស្រុកសន្ទុក ឃុំក្ដីដូង និង ឃុំព្រៃគុយ បញ្ចូលទៅក្នុងស្រុកកំពង់ស្វាយ នៃខេត្តកំពង់ធំ។

www.pheakdeylaw.com

មាត្រា ២.-

ត្រូវបានប្តូរស្រុកស្ទឹងសែន ទៅជា ក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងស្ទឹងសែន ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ៣.-

ត្រូវបានប្តូរ ឃុំចំនួនប្រាំបីនៃ ក្រុងស្ទឹងសែន ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

១- ឃុំកំពង់រទេះ	ទៅជា	សង្កាត់កំពង់រទេះ
២-ឃុំកំពង់ធំ	ទៅជា	សង្កាត់កំពង់ធំ
៣- ឃុំដីរជាន់ខ្លា	ទៅជា	សង្កាត់ដីរជាន់ខ្លា
៤-ឃុំអូរកន្ធរ	ទៅជា	សង្កាត់អូរកន្ធរ
៥-ឃុំកំពង់ក្របៅ	ទៅជា	សង្កាត់កំពង់ក្របៅ
៦-ឃុំព្រៃតាហ៊ូ	ទៅជា	សង្កាត់ព្រៃតាហ៊ូ
៧-ឃុំអាចារ្យលាក់	ទៅជា	សង្កាត់អាចារ្យលាក់
៨-ឃុំស្រយ៉ូវ	ទៅជា	សង្កាត់ស្រយ៉ូវ

មាត្រា ៤.-

ត្រូវផ្ទេរទីតាំងសាលាស្រុកស្ទឹងសែន ដែលស្ថិតនៅក្នុងសង្កាត់កំពង់រទេះ ទៅជាសាលា ក្រុងស្ទឹងសែន ។

មាត្រា ៥.-

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងស្ទឹងសែន ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តកំពង់ធំ អភិបាលក្រុងស្ទឹងសែន អភិបាលស្រុកសន្ទុក អភិបាលស្រុកកំពង់ស្វាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៩

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន